# សន្លឹកព័ត៌មានទី ៣៖ អំពីការបោះឆ្នោត (ការបោះឆ្នោតតាមរដ្ឋ)

នៅរដ្ឋអូស្ត្រាលីខាងលិច សភាចែកចេញជា ២ថ្នាក់។

ថ្នាក់ក្រោមមានឈ្មោះថា សភាបញ្ញត្តិ ដែលមានសមាជិក 59 នាក់។

សមាជិកសភានីមួយៗ ត្រូវបានជ្រើសរើសធ្វើជាតំណាងឲ្យតំបន់មួយ ក្នុងចំណោមតំបន់បោះឆ្នោតចំនួន 59 ។

ថ្នាក់លើមានឈ្មោះថា ក្រុមប្រឹក្សានីតិបញ្ញត្តិ។

ថ្នាក់នេះមានសមាជិក 36នាក់ ដោយក្នុងនោះ មានសមាជិក 6 នាក់ជាប់ឆ្នោតជាតំណាងឲ្យតំបន់ធំនីមួយៗក្នុងចំណោមតំបន់ធំ 6 ។

អ្នកបោះឆ្នោតឲ្យបេក្ខជនដែលចង់ធ្វើតំណាងតំបន់ ឬ តំបន់ធំ ដែលអ្នករស់នៅ។ អ្នកឈ្នះនឹងក្លាយជាសមាជិកជាប់ឆ្នោត។

នៅក្នុងការបោះឆ្នោតសកល អ្នកត្រូវបោះឆ្នោតរើសតំណាងរបស់អ្នកនៅក្នុង៖

- សភាតំណាងតំបន់របស់អ្នក
- ក្រុមប្រឹក្សាបញ្ញត្តិតំណាងតំបន់របស់អ្នក

ដើម្បីបោះឆ្នោតបាន អ្នកនឹងទទួលបានសន្លឹកឆ្នោតពីរសន្លឹក។

សន្លឹកឆ្នោតតូច ពណ៌ស សម្រាប់ការបោះឆ្នោតសភា(តំបន់របស់អ្នក)។

សូមអានការណែនាំដោយប្រុងប្រយ័ត្ន។

សូមប្រើតែតួលេខប៉ុណ្ណោះ។

ចាប់ផ្តើមពីលេខ “1”, សូមសរសេរលេខក្នុងប្រអប់ទាំងអស់តាមលំដាប់នៃជម្រើសរបស់ អ្នក។

សន្លឹកឆ្នោត ធំ ហើយមានពណ៌ សម្រាប់បោះឆ្នោតក្រុមប្រឹក្សានីតិបញ្ញត្តិ(ថ្នាក់តំបន់របស់អ្នក)

សូមអានការណែនាំដោយប្រុងប្រយ័ត្ន។

សូមប្រើតែតួលេខប៉ុណ្ណោះ។

អ្នកមានជម្រើស២ ក្នុងការគូសសន្លឹកឆ្នោត

អ្នកអាចសរសេរលេខ “1” ក្នុងប្រអប់ដែលនៅជាប់នឹងគណបក្ស ឬ ក្រុមនៅលើបន្ទាត់ទៅតាមជម្រើសរបស់អ្នក។

ឬ

អ្នកអាចបង់លេខក្នុងប្រអប់ទាំងអស់ នៅក្រោមបន្ទាត់ទៅតាមជម្រើសរបស់អ្នក។ អ្នកក៏អាចសួរមន្ត្រីនៅកន្លែងបោះឆ្នោតឲ្យជួយអ្នកបានគ្រប់ពេល។

**ដើម្បីក្លាយទៅជាបេក្ខជនឈរឈ្មោះឲ្យគេបោះឆ្នោត**

ដើម្បីក្លាយទៅជាបេក្ខជនឈរឈ្មោះឲ្យគេបោះឆ្នោត អ្នកត្រូវចុះឈ្មោះបោះឆ្នោត។

សូមអាន "អំពីការចុះឈ្មោះ" ដើម្បីដឹងពីព័ត៌មានបន្ថែមពីរបៀបនៃការចុះឈ្មោះ។

ដើម្បីឈរឈ្មោះ អ្នកត្រូវ៖

- បំពេញទម្រង់បែបបទតែងតាំង
- ផ្តល់ព័ត៌មានគ្រប់យ៉ាង តាមការស្នើសុំ
- បង់ប្រាក់កក់

ចំនួនទឹកប្រាក់ដែលអ្នកបង់អាស្រ័យទៅតាមថ្នាក់ដែលអ្នក ឈរឈ្មោះថាតើសម្រាប់ថ្នាក់រដ្ឋសហព័ន្ធ ឬរដ្ឋាភិបាលមូលដ្ឋាន។

អ្នកអាចឈរឈ្មោះដោយ ខ្លួនឯង ឬ អាចចូលក៏ឈរជាសមាជិកនៃគណបក្សនយោបាយ ឬក្រុមណាមួយ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ www.elections.wa.gov.au ឬ ទូរស័ព្ទទៅលេខ 13 63 06 ឬ (08) 9214 0400 សម្រាប់អ្នកទូរស័ព្ទឆ្លងរដ្ឋ។